**សកម្មភាព** ៖ **ល្បែងបង្កើតដីឥដ្ឋសូនរូប**

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

ការរស់នៅប្រចាំថ្ងៃ (ការស្វែងយល់ដោយសង្កេត)

**គោលបំណង** ៖

**(សិក្សាសង្គម)** ប្រាប់ពីរបៀប រចនា បង្កើតជារូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលបង្កើតឡើងបាន។

ប្រាប់បានពីរបៀបសូនរូបជារាងងាយៗដោយប្រើដៃទាំងពីរ។

ប្រាប់បានពីរបៀបនៃការពិសោធន៍ និងស្វែងយល់ពីរបរិស្ថាន។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី? "

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កូនចានដែកសម្រាប់លាយម្សៅមី ប្រេងឆា អំបិល ទឹកពណ៌លាក់)ទៅតាមចំនួនក្រុមនៃសិស្ស។

**ការរៀបចំ** ៖ ត្រៀមសម្ភារគ្រប់គ្រាន់ និងរៀបចំទឹកសម្រាប់ទុកលាងសម្អាតដៃរបស់ក្មេងៗទាំងអស់។

**សេក្តីណែនាំ** ៖

1. សួរក្មេងៗថា៖ តើកូនៗនៅចាំការងារដំបូងរបស់លោកគ្រូសុខដែរឬទេ?
2. ប្រាប់ក្មេងថា៖ ថ្ងៃនេះកូនៗនឹងលេងល្បែងធ្វើដីឥដ្ឋជាមួយអ្នកគ្រូ។
3. កូនៗការពិសោធន៍នេះគឺកូនអនុវត្តដោយខ្លួនឯងផ្ទាល់។
4. សួរក្មេងៗថា៖ តើកូនៗត្រូវមានគ្រឿងផ្សំអ្វីខ្លះដើម្បីបង្កើតដីឥដ្ឋ?
   (បើក្មេងមិនដឹងយើងអាចប្រាប់បាន ម្សៅមី ប្រេងឆា អំបិល ទឹក ពណ៌លាក់)
5. ចែកក្មេងៗជា១ ក្រុម ៥នាក់តាមស្ថានភាពជាក់ស្តែង ។
6. យើងជាអ្នកបង្ហាញត្រូវលាយម្សៅក្នុងចានដែកមួយ ដើម្បីបង្ហាញក្មេងៗពីរបៀបលាយ។
7. ឱ្យចានដែកតូចទៅក្មេងៗតាមក្រុមនីមួយៗ ។
8. លាយម៉្សៅមីតាមចានដែកនៃក្រុមនីមួយៗដូចខាងក្រោម៖
   (បរិមាណម្សៅមីគឺអាស្រ័យទៅលើទំហំចានដែក និងចំនួនសិស្សតាមក្រុម)
   a. ម្សៅមី ២កែវ

b. អំបិល ១/២កែវ

c. ប្រេងឆា ២ស្លាបព្រា

d. ទឹក ២កែវ

e. អាចបន្ថែមពណ៌លាក់ដើម្បីសូនរូបភាពផ្សេងៗបានស្អាត។

9. បរិមាណអំបិលត្រូវលាយច្របល់ជាមួយម្សៅមី ពេលដាក់ចូលតាមចានដែកនីមួយៗ ។

10. រួចត្រូវចាក់ប្រេងឆា ឬ ខ្លាញ់ដើម្បីកុំឱ្យស្អិតជាប់ប្រតាក។

11. ដាក់លាយទឹកបន្តិច បន្ថែមពណ៌លាក់ តាមសាច់ម្សៅមីពេលយើងច្របល់ចូលគ្នា។

12. បង្ហាញក្មេងៗថា៖ ដីឥដ្ឋអាចសូនធ្វើជារូបសត្វផ្សេងៗបានទាល់តែដីឥដ្ឋនោះមានសភាពរឹងល្មម។

13. មើលក្មេងលេង និងជួយប្រសិនបើក្រុមណាបានដាក់ទឹកច្រើនពេក អ្នកអាចថែមម្សៅមីបាន។

14. អ្នកអាចឱ្យក្មេងៗសូនរូបជានំខេក ឬ ជានំប៉័ងក៏បានដែរ ។

15. ក្មេងៗអាចយកដីឥដ្ឋទៅផ្ទះ និងដាក់ហាលរូបសូនរួចនៅក្នុងថ្នាក់ ដើម្បីទុកលាបពណ៌នៅថ្ងៃក្រោយ។

16. បង្រៀនក្មេងៗរៀបចំចានដែកឱ្យបានស្អាត និងដីឥដ្ឋឱ្យបានត្រឹមត្រូវបន្ទាប់ពីលេងរួច។